**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ ស្តីពីការកំណត់ការចំណាយដោយឡែក សម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៅក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងនិងក្រៅប្រទេស
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អាហារូបករណ៍និងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះអ្នកសិក្សា ដើម្បីទំនុកបម្រុងការសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

- ផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាកម្រិតបឋមសិក្សាឯកទេស កម្រិតមធ្យមសិក្សាឯកទេស កម្រិតបរិញ្ញាបត្រ និងកម្រិតក្រោយបរិញ្ញាបត្រ
- ផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអ្នកសិក្សាដែលទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងមន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស ស្របតាមច្បាប់ស្តីពីការអប់រំ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ មានភ្ជាប់ជាឧបសម្ព័ន្ធ។

## ជំពូកទី២
## កម្រិតនិងលក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក

**មាត្រា៥ .-**

អាហារូបករណ៍ប្រចាំខែរបស់សិស្សនិងនិស្សិត ដែលបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេសសាធារណៈ ត្រូវកំណត់តាមកម្រិតដូចខាងក្រោម៖

- ក្រោយបរិញ្ញាបត្រ : ៨០ ០០០រៀល

- បរិញ្ញាបត្រ : ៤៥ ០០០រៀល
- មធ្យមសិក្សាឯកទេស : ៤០ ០០០រៀល
- បឋមសិក្សាឯកទេស : ៣០ ០០០រៀល។

**មាត្រា៦ .-**

ចំនួនសិស្សនិងនិស្សិតដែលទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ៖

- កម្រិតក្រោយបរិញ្ញាបត្រ : ២៥ភាគរយ
- កម្រិតបរិញ្ញាបត្រ : ១០ភាគរយ
- កម្រិតមធ្យមសិក្សាឯកទេស : ៣០ភាគរយ
- កម្រិតបឋមសិក្សាឯកទេស : ៣៥ភាគរយ។

ចំពោះសិស្សនិងនិស្សិត ដែលទទួលការបណ្តុះបណ្តាលមុខជំនាញដែលរាជរដ្ឋាភិបាលកំណត់ថាជាមុខជំនាញអាទិភាព ឬមុខជំនាញចាំបាច់សម្រាប់សង្គម ដូចជាកីឡានិងគ្រូបង្រៀនគ្រប់កម្រិត ត្រូវទទួលអាហារូបករណ៍មួយរយភាគរយ។

**មាត្រា៧ .-**

ការផ្តល់អាហារូបករណ៍ប្រចាំខែ ត្រូវអនុវត្តតែក្នុងរយៈពេលកំពុងសិក្សា។ ពេលឈប់សម្រាកក្នុងឱកាសមហាវិស្សមកាលនិងពេលព្យួរការសិក្សា សិស្សនិងនិស្សិតមិនត្រូវបានទទួលប្រាក់អាហារូបករណ៍ឡើយ។

ក្នុងករណីសិស្ស និស្សិតដែលរៀនត្រួតថ្នាក់ រដ្ឋនឹងផ្តាច់អាហារូបករណ៍វិញ លើកលែងតែគរុសិស្សនិងគរុនិស្សិត។

**មាត្រា៨ .-**

ការផ្តល់អាហារូបករណ៍ ត្រូវអនុវត្តតាមគោលការណ៍អាទិភាព ដូចខាងក្រោម៖

១- សិស្ស និស្សិត គោរពវិន័យបានល្អនិងរៀនពូកែ។

២- កូនកំព្រាឪពុកនិង/ឬម្តាយ មានជីវភាពក្រីក្រ។

៣- កូនជនជាតិដើមភាគតិច។

៤- សិស្ស និស្សិតដែលមកពីគ្រួសារក្រីក្រ។

ក្នុងអាទិភាពទាំង៤ខាងលើ នារីភេទត្រូវបានយកចិត្តទុកដាក់មុនគេ។

**មាត្រា៩ .-**

ការកំណត់ឈ្មោះសិស្សនិងនិស្សិតដែលត្រូវបានទទួលអាហារូបករណ៍ និងការពិនិត្យវាយតម្លៃផ្តល់អាទិភាពដូចក្នុងមាត្រា៦និងមាត្រា៨នៃអនុក្រឹត្យនេះ ត្រូវរៀបចំមួយឆ្នាំម្តង ដោយគ[illegible] ជ្រើសរើសអាហារូបករណ៍របស់គ្រឹះស្ថានសិក្សា។

នីតិវិធីនិងការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការជ្រើសរើសអាហារូបករណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ។

**មាត្រា១០ .-**

គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ដែលបានប្រែក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រើថវិការបស់ខ្លួនក្នុងការរ៉ាប់រងបើកប្រាក់អាហារូបករណ៍ប្រចាំខែជូនដល់សិស្ស និស្សិតអាហារូបករណ៍ដែលកំពុងសិក្សា ដូចមានកំណត់នៅមាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨នៃអនុក្រឹត្យនេះ។

**មាត្រា១១ .-**

ចំពោះមន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស រយៈពេលពី០១(មួយ)ថ្ងៃដល់១០(ដប់)ថ្ងៃ ត្រូវទទួលប្រាក់ស្នាក់នៅនិងប្រាក់បេសកកម្មតាមច្បាប់រដ្ឋ។ អ្នកចូលរួមដែលមានទីលំនៅនៅជិតជាង១០គីឡូម៉ែត្រ ត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន១០ ០០០(មួយម៉ឺន)រៀល ក្នុងមួយថ្ងៃ។

ចំណែកឯវគ្គសិក្សាដែលមានរយៈពេលចាប់ពី១១(ដប់មួយ)ថ្ងៃរហូតដល់តិចជាង១២(ដប់ពីរ)ខែ ត្រូវទទួលប្រាក់ឧបត្ថម្ភអន្តេវាសិកចំនួន៨ ០០០(ប្រាំបីពាន់)រៀលក្នុងមួយថ្ងៃ ដោយមិនអនុញ្ញាតឱ្យទទួលរបបបេសកកម្មតាមការកំណត់របស់រដ្ឋបន្ថែមទៀតឡើយ។ អ្នកចូលរួមដែលមានទីលំនៅនៅជិត អាចមកស្នាក់នៅផ្ទះរបស់ខ្លួនបានក្នុងរាជធានី ខេត្ត ត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន៥ ០០០(ប្រាំពាន់)រៀល ក្នុងមួយថ្ងៃ ហើយផ្តល់ជូនសម្រាប់ថ្ងៃបំពេញការងារ។

**មាត្រា១២ .-**

សិស្សជនជាតិដើមភាគតិចនិងសិស្សមានជីវភាពក្រីក្រ ដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាននៃអនុវិទ្យាល័យ វិទ្យាល័យ ឬទីប្រជុំជនស្រុក ឃុំដែលមានអន្តេវាសិកដ្ឋាន ត្រូវបានទទួលប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃម្នាក់ៗចំនួន៤ ២០០(បួនពាន់ពីររយ)រៀល និងរបបឧបត្ថម្ភសម្រាប់សម្ភារៈដំណេកនិងសម្ភារៈសិក្សាប្រចាំឆ្នាំ ក្នុងម្នាក់ៗចំនួន១០០ ០០០(មួយសែន)រៀល។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅ។

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តអនុក្រឹត្យនេះ។

**មាត្រា១៤ .-**

អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## នៃអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៤

## ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិត សិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

**កម្រិតក្រោយបរិញ្ញាបត្រ** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រដែលមានតម្លៃស្មើធ្វើជាមូលដ្ឋាន សម្រាប់ទទួលការបណ្តុះបណ្តាលបន្ត និងមានរយៈពេលបណ្តុះបណ្តាល ចាប់ពី១ឆ្នាំឡើងទៅ។

**កម្រិតបឋមសិក្សាឯកទេស** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅឬបំពេញវិជ្ជា ឬសញ្ញាបត្រ ដែលមានតម្លៃស្មើធ្វើជាមូលដ្ឋានសម្រាប់ទទួលការបណ្តុះបណ្តាល និងមានរយៈពេលបណ្តុះបណ្តាលបន្តចាប់ពី៦ខែទៅ៣ឆ្នាំ ដោយផ្អែក ទៅតាមមុខជំនាញ។

**កម្រិតមធ្យមសិក្សាឯកទេស** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬបំពេញវិជ្ជា ឬសញ្ញាបត្រ ដែលមានតម្លៃស្មើធ្វើជាមូលដ្ឋានសម្រាប់ទទួលការបណ្តុះបណ្តាល និងមានរយៈពេលបណ្តុះបណ្តាលចាប់ពី២ឆ្នាំទៅ៤ឆ្នាំកន្លះ ដោយផ្អែក ទៅតាមមុខជំនាញ។

**របបឧបត្ថម្ភជីវភាព** សំដៅដល់ប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃ សម្ភារៈដំណេក និងសម្ភារៈ សិក្សាប្រចាំឆ្នាំ សម្រាប់ជួយទំនុកបម្រុងអ្នកសិក្សាដែលស្នាក់នៅអន្តេ-វាសិកដ្ឋាន។

**វគ្គបំប៉ន** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីផ្តល់នូវសំណុំចំណេះដឹង ជំនាញ និងតម្លៃ បំពេញបន្ថែមឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងភារកិច្ចដែលបានកំណត់។

**វគ្គវិក្រឹតការ** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីអភិវឌ្ឍវិជ្ជាជីវៈជាប់ជាប្រចាំតាម កាលកំណត់ឬការចាំបាច់របស់ក្រសួង ស្ថាប័ន។

**វគ្គសុក្រឹតការ** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីលើកកម្ពស់សមត្ថភាពឱ្យបាន ល្អប្រសើរជាងមុនសក្តិសមនឹងតួនាទីនិងភារកិច្ចដែលកំពុងបំពេញ ការងារ។

**សិក្ខាសាលា** សំដៅដល់ការប្រជុំដើម្បីផ្សព្វផ្សាយ ពិគ្រោះយោបល់ ផ្តោតនាំ-ផ្លាស់ប្តូរ បទពិសោធ...ដល់សិក្ខាកាមដែលបានកំណត់តាមមុខសញ្ញា។

**អាហារូបករណ៍** សំដៅដល់ប្រាក់ដែលផ្តល់ឱ្យដល់អ្នកសិក្សា ដើម្បីទំនុកបម្រុងការ សិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ។